2025



**របាយការណ៍សង្ខេប**

# កម្មករអេតចាយនៅកម្ពុជា

ស្ថានភាពរស់នៅ | ឋានៈសង្គម-សេដ្ឋកិច្ច | កិច្ចគាំពារសង្គម

របាយការណ៍ពេញ

Australian Aid

ស.ប.ឯ.ស IDEA

actionaid

**កំណត់សំគាល់៖**

ការស្រាវជ្រាវនេះត្រូវបានផ្តល់មូលនិធិដោយកម្មវិធីសហប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលី (ANCP)។ ទស្សនៈដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះគឺជាទស្សនៈរបស់អ្នកស្រាវជ្រាវ និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់កម្មវិធីសហប្រតិបត្តិការអង្គការមិនមែនរដ្ឋាភិបាលអូស្ត្រាលីឡើយ។

Australian AID    ស.ប.ឯ.ស IDEA    actionaid

# សេចក្តីសង្ខេបរបាយការណ៍ស្រាវជ្រាវ

## កម្មករអេតចាយ នៅកម្ពុជា៖
## ស្ថានភាពរស់នៅ ឋានៈសង្គម-សេដ្ឋកិច្ច
## អំពើហិង្សា និងកិច្ចគាំពារសង្គម

២០២៥

# មាតិកា

01 សារតា ........................................................................................................ 2
02 របកគំហើញពីការស្រាវជ្រាវ ........................................................................................ 3
របកគំហើញទី១៖ ស្ថានភាពរស់នៅមិនសមរម្យ, ហានិភ័យទាក់ទងនឹងការងារ, បំណុង និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាលំបាកបំបិន ........................................................................................ 3
របកគំហើញទី២៖ អំពើហិង្សា, ការបៀតបៀន និងការរើសអើង ........................................................ 5
របកគំហើញទី៣៖ កង្វះកិច្ចគាំពារសង្គម ........................................................................ 7
អនុសាសន៍ ........................................................................................................ 8
03 សេចក្តីសន្និដ្ឋាន ........................................................................................................ 10
ករណីសិក្សាទី១ ........................................................................................................ 11
ករណីសិក្សាទី២ ........................................................................................................ 16

គេហទំព័រ

# 01 សាវតា

កម្មករចំនួន ៨៨,៣ ភាគរយ បានចូលរួមក្នុងការងារក្រៅប្រព័ន្ធ (ក្នុងនោះ ៨៧,៦ ភាគរយជាស្ត្រី) ហើយគ្រឹះស្ថានចំនួន ៨៧,៦ ភាគរយ ស្ថិតនៅក្រៅប្រព័ន្ធ។ កម្មករអេតចាយ ត្រូវបានចាត់ថ្នាក់ថាជាការងារស្វ័យនិយោជន៍ ក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធក្នុងចំណោមកម្មករក្រៅប្រព័ន្ធផ្សេងទៀត ដូច្នេះហើយ ពួកគេមិនទាន់ត្រូវបានទទួលស្គាល់ថាជាកម្មករមានសិទ្ធិទទួលបានអត្ថប្រយោជន៍ផ្លូវការ ដូចកម្មករនិយោជិតដែលបានចុះបញ្ជីក្នុងច្បាប់ស្តីពីការងារដែលមានសិទ្ធិទទួលបាននៅឡើយទេ។ កម្មករអេតចាយដែលមានឋានៈការងារស្វ័យនិយោជន៍ ក្រោមវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធនេះ ធ្វើឲ្យពួកគេងាយរងគ្រោះនិងទទួលបានការយកចិត្តទុកដាក់តិចតួច ក្រោមស្ថានភាពជាច្រើន រួមទាំងឋានៈសង្គម, ការបៀតបៀន និងកង្វះលទ្ធភាពទទួលបានជំនួយសង្គមនិងកិច្ចគាំពារពារសង្គម។

នៅឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) បានដាក់ចេញនូវគម្រោងថែទាំសុខភាពដល់កម្មករនិយោជិតក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ហើយក្រោយមកទៀត លាតសន្ធឹងដល់សមាជិកគ្រួសាររបស់ពួកគេ។

.

# 02 របកគំហើញពីការស្រាវជ្រាវ

លទ្ធផលស្រាវជ្រាវបានមកពីការស្ទង់មតិកម្មករអេតចាយចំនួន ២៨៥ នាក់ក្នុងរាជធានីភ្នំពេញ ដែលក្នុងនោះ មាន ៦៥ ភាគរយជាស្ត្រី និង ៣៥ ភាគរយជា បុរស, កិច្ចពិភាក្សាជាក្រុម (FGD) ចំនួន ៧ ដែលមានអ្នកចូលរួមចំនួន ៥៦ នាក់ និងតំណាងមួយចំនួនមកពីសហជីពនិងអង្គការសង្គមស៊ីវិល (CSO)។ ការស្រាវជ្រាវនេះមានគោលបំណង (១) ប៉ាន់ប្រមាណស្ថានភាពរស់នៅរបស់កម្មករអេតចាយ, តម្រូវការ, ហានិភ័យដែលទាក់ទងនឹងការងារ និងវិធីដោះស្រាយបញ្ហា។ (២) ស្វែងកំណត់អំពីគម្រោងសមរម្យសម្រាប់កម្មករអេតចាយ, លទ្ធភាពក្នុងការរួមចំណែកបង់ភាគទានជាទៀងទាត់ និងកម្រិតនៃភាគទានដែលពួកគេពេញចិត្ត ដោយផ្អែកលើប្រាក់ចំណូល, ពិនិត្យមើលឧបសគ្គដែលរារាំងសមត្ថភាពរបស់កម្មករអេតចាយ ក្នុងការបង់ភាគទានដល់បេឡាជាតិសន្តិសុខសង្គម និងឧបសគ្គក្នុងការពង្រីកការគ្របដណ្តប់របស់ពួកគេ និង (៣) ស្វែងយល់អំពីបទពិសោធន៍នៃអំពើហិង្សាយេនឌ័រ, ការបៀតបៀន និងការរើសអើងលើស្ត្រីកម្មករអេតចាយនៅកន្លែងការងាររបស់ពួកគេ។

## របកគំហើញទី១៖ ស្ថានភាពរស់នៅមិនសមរម្យ, ហានិភ័យទាក់ទងនឹងការងារ, បំណុល និងយុទ្ធសាស្ត្រដោះស្រាយបញ្ហាលំបាកបំបិន

ការសិក្សានេះបានរកឃើញថា កម្មករអេតចាយរស់នៅក្នុងស្ថានភាពមិនច្បាស់លាស់ ដោយក្នុងនោះ មាន ៦០% ជួលផ្ទះស្នាក់នៅ, ២៧% រស់នៅផ្ទះខ្លួនឯង និងអ្នកផ្សេងទៀតរស់នៅក្នុងឃ្លាំងអេតចាយ ឬមិនមានទីជម្រកទៀងទាត់។ កម្មករស្ទើរតែទាំងអស់ធ្វើការប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ជាញឹកញាប់គឺលើសពី ១០ម៉ោង ក្នុងមួយថ្ងៃ ដោយឈប់សម្រាកតែនៅពេលឈឺជំងឺ ឬថ្ងៃបុណ្យទានសំខាន់ៗតែប៉ុណ្ណោះ ខណៈដែលភាគច្រើនរកចំណូលបានចន្លោះពី $១,២៥ ទៅ $១២,៥០ ជារៀងរាល់ថ្ងៃ ហើយចំណូលទាំងនេះ មិនគ្រប់គ្រាន់សម្រាប់តម្រូវការចាំបាច់ទេ។ ការជំពាក់បំណុល កើតឡើងយ៉ាងសាយភាយ ដោយក្នុងនោះ ៦៩% ជំពាក់ប្រាក់ម្ចាស់កម្ចីផ្សេងៗ ក្រោមលក្ខខណ្ឌនៃការសងដែលអាចមានលក្ខណៈបត់បែន ប៉ុន្តែជាបន្ទុកដ៏ធ្ងន់។ អសន្តិសុខស្បៀង និងអាហារូបត្ថម្ភមិនគ្រប់គ្រាន់កើតឡើងជាធម្មតា ហើយកម្មករអេតចាយតែងតែប្រឈមមុខនឹងការរងរបួស, បរិយាកាសការងារអសុវត្ថិភាព និងការលួច។ បញ្ហាសុខភាពប៉ះពាល់ដល់ អ្នកចូលរួមការស្ទង់មតិចំនួន ៥៩% នៃ ប៉ុន្តែមានមនុស្សតិចណាស់ដែលបានទទួលការថែទាំសុខភាពជាផ្លូវការ ហើយជាទូទៅពឹងផ្អែកលើឱសថស្ថានសម្រាប់ការព្យាបាលចាំបាច់។

**របកគំហើញសំខាន់ៗ៖**

- ៦០% ជួលផ្ទះស្នាក់នៅ, ២៧% រស់នៅផ្ទះខ្លួនឯង, ៧% រស់នៅក្នុងឃ្លាំងអេតចាយ និង ៦% មិនមានជម្រកទៀងទាត់ទេ គឺស្នាក់នៅលើទូក, តាមដងផ្លូវ, សួនច្បារ ឬរទេះអេតចាយ។
- ៩៦,២% នៃអ្នកផ្តល់សម្ភាស ធ្វើការប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ជាញឹកញាប់លើសពី ១០ ម៉ោងជារៀងរាល់ថ្ងៃ។ ការឈប់សម្រាកពីការងារ ជាទូទៅ គឺដោយសារឈឺ, ហត់នឿយខ្លួនពេក ឬក្នុងពេលបុណ្យជាតិសំខាន់ៗតែប៉ុណ្ណោះ។ កម្មករអេតចាយជាច្រើនបន្តធ្វើការច្រើនម៉ោងដោយសង្ឃឹមថានឹងអាចរកអេតចាយកាន់តែច្រើន និងបង្កើនប្រាក់ចំណូលរបស់ខ្លួន។
- ជាង ៩៩% នៃអ្នកឆ្លើយសំណួរបានលើកឡើងថា ប្រាក់ចំណូលរបស់ពួកគេមិនគ្រប់គ្រាន់ក្នុងការចំណាយប្រចាំថ្ងៃទេ។ ភាគច្រើនរកបានចន្លោះពី ១០.០០០ រៀង ទៅ ២០,០០០ រៀល (២,៥០–៥.០០ ដុល្លារ) ក្នុងមួយថ្ងៃ ដោយក្នុងនោះប្រាក់ចំណូលមានក្នុងចន្លោះពី ៥.០០០–៥០.០០០ រៀល (១,២៥ ទៅ ១២,៥០ ដុល្លារ)។
- ៦៩% នៃអ្នកឆ្លើយតបបានរាយការណ៍ថាកំពុងជំពាក់បំណុលធនាគារ, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ, សាច់ញាតិ, ម្ចាស់អាជីវកម្មអេតចាយ និងអ្នកផ្តល់ប្រាក់កម្ចីឯកជន។ លក្ខខណ្ឌនៃការសងប្រាក់មានភាពផ្សេងៗគ្នា ដូចជាការទូទាត់បង់ប្រចាំខែសម្រាប់ធនាគារ និងមីក្រូហិរញ្ញវត្ថុ និងការបង់ដែលអាចបត់បែនបានដូចជា ត្រូវបង់ប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬតាមដែលអាចលៃលកបង់បាន សម្រាប់អ្នកផ្តល់ប្រាក់កម្ចីឯកជន។
- ភាគច្រើនមិនមានអាហារគ្រប់គ្រាន់ទេ ទាំងបរិមាណនិងអាហារូបត្ថម្ភ។
- កម្មករអេតចាយប្រឈមមុខនឹងការរងរបួសប្រចាំថ្ងៃ ដោយសារតែកង្វះឧបករណ៍ការពារ។ នៅកន្លែងចាក់សំរាម គ្រោះថ្នាក់តែងតែកើតឡើងដោយសារតែអ្នកបើកបរឡានដឹកសំរាមមានការធ្វេសប្រហែស ឬកម្មករអេតចាយគេចចេញមិនទាន់ពេល។ អ្នកខ្លះក៏ធ្លាប់រងការលួចទ្រព្យសម្បត្តិផ្ទាល់ខ្លួន ឬលុយដោយសារខ្វះកន្លែងទុកដាក់ដែលមានសុវត្ថិភាព។
- ៥៩% បានរាយការណ៍អំពីបញ្ហាសុខភាព ទោះបីជាគ្មាននរណាម្នាក់បានពិនិត្យសុខភាពទៀងទាត់ក៏ដោយ។ ភាគច្រើនពឹងផ្អែកលើឱសថស្ថានក្បែរៗខ្លួន សម្រាប់ការបំបាត់ការឈឺចាប់ភ្លាមៗតាមរោគសញ្ញាដែលបានលេចឡើង, ហើយពួកគេទៅគ្លីនិកឬមន្ទីរពេទ្យ តែនៅពេលចាំបាច់ ឬនៅពេលត្រូវសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។

## របកគំហើញទី២៖ អំពើហិង្សា, ការបៀតបៀន និងការរើសអើង

បុរសនិងស្ត្រីភាគច្រើនជឿថាពួកគេប្រឈមមុខនឹងការលំបាកដូចគ្នា។ ពួកគេយល់ឃើញថា ការបំពាន និងការរើសអើងបានកើតឡើងជាទម្លាប់ទៅហើយ គឺថា កម្មករអេតចាយមានអារម្មណ៍ថាគ្មានអំណាចក្នុងការទប់ទល់ជំនះនោះទេ ហើយបានចុះចាញ់ចំពោះជីវិត ដែលសង្គមនេះបានកំណត់ដាក់មកលើមកគេរួចទៅហើយនោះ។ ស្ត្រីកម្មករអេតចាយ បានរាយការណ៍អំពីការបៀតបៀនតាមពាក្យសម្តី បៀតបៀនផ្លូវចិត្ត និងជួនកាលបៀតបៀនផ្លូវភេទ ដែលជាញឹកញាប់បានកើតឡើងដោយសារតែការវិនិច្ឆ័យទៅលើការងារ, រូបរាង និងអាកប្បកិរិយារបស់ពួកគេ។ ស្ត្រីជាង ៣០% បានប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ ដោយករណីខ្លះកើនឡើងរហូតដល់ការរំលោភបំពានធ្ងន់ធ្ងរនិងការលែងលះទៀតផង។ ការរើសអើងក៏រីករាលដាលដល់សមាជិកគ្រួសារ និងកូនរបស់ពួកគេទៀតផង។

**របកគំហើញសំខាន់ៗ៖**

- កម្មករអេតចាយតែងប្រឈមមុខនឹងអំពើហឹង្សាលើរាងកាយពីក្រុមក្មេងទំនើង ដែលជាញឹកញាប់ក្នុងអំឡុងពេលត្រូវក្រុមទំនើងមកលួច ឬការវាយដំដោយគ្មានការបង្ករឿងហេតុទៀតផង។ ជម្លោះជុំវិញការរើសអេតចាយបានកើតឡើងជាធម្មតាទៅហើយ ហើយស្ត្រីជាច្រើនរាយការណ៍ថាមានអំពើហិង្សាក្នុងគ្រួសារពីដៃគូរបស់ពួកគេ។
- ៣១.៦% នៃអ្នកឆ្លើយតបជាស្ត្រីបានរាយការណ៍ថា បានទទួលរងអំពើហឹង្សាក្នុងគ្រួសារដែលប្រព្រឹត្តដោយដៃគូ/ប្តីឬប្រពន្ធរបស់ពួកគេ។
- កម្មករអេតចាយបានរាយការណ៍អំពីការបំពានពាក្យសម្តី និងផ្លូវអារម្មណ៍ជាញឹកញាប់ ហើយត្រូវបានគេជេរប្រមាថ និងមើលងាយដោយសារតែការងារ, រូបរាង និងអាកប្បកិរិយារបស់ពួកគេ ជាទម្លាប់ទៅហើយ។ ខណៈពេលដែលអ្នកខ្លះបាននិយាយថា ពួកគេមិនដែលប្រឈមមុខនឹងការធ្វើបាបខ្លាំងក៏ដោយ ក៏ភាគច្រើនបានពិពណ៌នាថា បានទទួលរងការស្តីបន្ទោសពីប្រជាជន, អាជ្ញាធរ និងកម្មករឡានដឹកសំរាម នៅពេលមានសំរាមរប៉ាត់រប៉ាយជុំវិញទីតាំងទុកសំរាមទាំងនោះ ។

- កម្មករអេតចាយជាច្រើននាក់បានចែករំលែកអំពីបទពិសោធន៍ដែលត្រូវគេដេញចេញ, គេចោទថាជាចោរលួច និងទទួលរងការគំរាមកំហែងថាគេនឹងរាយការណ៍ប្រាប់ប៉ូលីសជាដើម ដោយពួកគេគ្រាន់តែដើររើសសំរាមទាំងនោះសោះ។ អ្នកឆ្លើយតបម្នាក់បាននិយាយថា *«ពេលខ្លះ ម្ចាស់ផ្ទះនិយាយត្រង់មកយើងថា 'ហេ អាចោរ/មីចោរ ឯងចង់លួចអ្វី?»* ហើយនេះជាការរំលេចឡើងនូវការប្រមាថមើលងាយនិងភាពប្រទូស្តរាយដែលពួកគេត្រូវតែខំទ្រាំរាល់ថ្ងៃ។

- កម្មករអេតចាយបានចែករំលែកបទពិសោធន៍ចម្រុះជាមួយអ្នកជិតខាងរបស់ពួកគេ — អ្នកខ្លះបានរៀបរាប់អំពីសេចក្ដីសប្បុរស, ការទទួលអាហារ, ឱសថ, សម្លៀកបំពាក់ និងជំនួយដល់កូនរបស់ពួកគេ ជាពិសេសនៅពេលឈឺ។ យ៉ាងណាក៏ដោយ អ្នកខ្លះទៀតប្រឈមមុខនឹងការរងភាពអាម៉ាស់ជារៀងរាល់ថ្ងៃ ដោយអ្នកជិតខាងប្រើសម្ដីមិនល្អ ពេលខ្លះហៅពួកគេថាជាចោរ និងមើលងាយក្រុមគ្រួសាររបស់ពួកគេក៏មាន។ កម្មករអេតចាយជាច្រើន បាននិយាយរៀបរាប់អំពីការឈឺចាប់យ៉ាងខ្លាំងដែលបណ្ដាលមកពីការមិនឱ្យតម្លៃលើការងាររបស់ពួកគេ ដូចអ្នកឆ្លើយតបម្នាក់បាននិយាយថា *«ជាការលំបាកក្នុងការទទួលយកការមើលងាយមកលើយើងណាស់។ មានពេលខ្លះ ខ្ញុំគិតចង់សម្លាប់ខ្លួនទៀតផង"*។ បុរេនិច្ឆ័យទាំងនេះ បានរីកដាល់ដល់កូនៗរបស់ពួកគេទៀតផង ដែលត្រូវបានលាបពណ៌យ៉ាងសាហាវថា *«អា/មីកូនអ្នករើសអេតចាយ»*។ បទពិសោធន៍ទាំងនេះឆ្លុះបញ្ចាំងកង្វះខាងនូវទង្វើដែលបង្ហាញភាពអាណិតអាសូរ និងការផាត់ចេញពីសង្គមដ៏ឈឺចាប់និងជាប្រចាំ។

## របកគំហើញទី៣៖ កង្វះកិច្ចគាំពារសង្គម

ស្ទើរតែពីរភាគបីនៃអ្នកតបសម្ភាសមិនមានប័ណ្ណក្រីក្រ ដែលផ្តល់ឱ្យពួកគេទទួលបានសេវាថែទាំសុខភាពដោយឥតគិតថ្លៃនោះទេ។ គម្រោងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស.) សម្រាប់បុគ្គលស្វ័យនិយោជន៍ត្រូវបានដាក់ឱ្យដំណើរការនៃពេលថ្មីៗនេះ។ កម្មកររអេតចាយតិចតួចណាស់ដឹងពីអត្ថិភាព នីតិវិធី ឬអត្ថប្រយោជន៍នានា។ អ្នកតបសម្ភាសភាគច្រើន អាចមានលទ្ធភាពបង់ភាគទានតិចតួចដល់ ប.ស.ស ខណៈពេលដែលអ្នកខ្លះមិនប្រាកដថាអាចបង់បានឬទេ ឬមិនអាចបង់បាន។ លើសពីនេះទៀត ការជឿទុកចិត្តតិចតួចទៅលើសេវាថែទាំសុខភាពនៅមូលដ្ឋាន និងការចំណាយខ្ពស់ ព្រមទាំងការបាត់បង់ប្រាក់ចំណូល ដោយសារតែការចំណាយពេលធ្វើដំណើរទៅកាន់មន្ទីរពេទ្យរដ្ឋធំៗនោះ ក៏កាន់តែបានបង្អាក់ទឹកចិត្តក្នុងការចូលរួមនេះដែរ។

**របកគំហើញសំខាន់ៗ៖**

- អ្នកតបសម្ភាស ៧១% មិនមានប័ណ្ណក្រីក្រ ដែលជាញឹកញាប់បានកើតឡើងដោយសារតែខ្វះការយល់ដឹង, ឯកសារមិនគ្រប់គ្រាន់ ឬការបដិសេធដោយអាជ្ញាធរមូលដ្ឋាន។
- ៩១% មិនបានដឹងអំពីគម្រោង ប.ស.ស ផ្នែកស្វ័យនិយោជន៍នៅឡើយទេ។
- មានអ្នកតបសម្ភាសតែ ២% ប៉ុណ្ណោះ ក្នុងការសិក្សានេះដែលបានចុះឈ្មោះជាមួយ ប.ស.ស។
- សម្រាប់អ្នកតបសម្ភាសភាគច្រើន ពួកគេមិនអាចមានលទ្ធភាពបង់ភាគទាន ប.ស.ស នោះទេ ជាពិសេសនៅពេលដែលត្រូវបង់ឲ្យសមាជិកផ្សេងទៀតក្នុងគ្រួសារនោះ។
- មានអ្នកតបសម្ភាសតែ ១២% ប៉ុណ្ណោះដែលបានលើកឡើងថាអាចមានលទ្ធភាពបង់ថ្លៃសេវាប្រចាំខែ ប.ស.ស ផ្នែកស្វ័យនិយោជន៍ ក្នុងចំណែក ១៥.៦០០០ រៀល (ប្រហែល ៣.៩០ ដុល្លារ) ខណៈដែល ៨៨% រាយការណ៍ថាមិនអាចបង់ប្រាក់បាន ហើយត្រូវការជំនួយសម្រាប់ការបង់នេះ។
- ៥០% បានលើកឡើងថា អាចបង់ប្រាក់ពី ៤.០០០ ទៅ ៨.០០០ រៀល ($១-$២) ខណៈដែល ២៥% បានលើកឡើងថាពួកគេអាចបង់ ១០.០០០ រៀល ($២,៥០)។ ១៣% បានលើកឡើងថាពួកគេមិនអាចបង់ប្រាក់បានទេ ខណៈដែល ១៣% ទៀតមិនទាន់ដឹងថាពួកគេអាចបង់បានក្នុងចំនួនប៉ុន្មាននៅឡើយទេ។

# អនុសាសន៍

- **អនុម័តយកយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដែលដែលបង្កលក្ខណៈងាយស្រួលនិងប្រកបដោយបរិយាបន្ន៖** ប្រើប្រាស់ការផ្សព្វផ្សាយតាមពាក្យសម្ដី, ជារូបភាពមើលឃើញ, ជាសំឡេង និងតាមសហគមន៍ ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីអត្ថប្រយោជន៍នៃកិច្ចគាំពារសង្គម, សេវាថែទាំសុខភាព និងសិទ្ធិកម្មករ។ ផ្ដល់អាទិភាពក្នុងការប្រើប្រាស់ទម្រង់ដែលងាយស្រួលសម្រាប់អ្នកចេះអក្សរតិចតួច និងយុទ្ធនាការអប់រំផ្ដោតលើគោលដៅជាក់លាក់ ដើម្បីបង្កើនការយល់ដឹងអំពីអត្ថប្រយោជន៍, នីតិវិធី និងសិទ្ធិទទួលបាន ទាក់ទងនឹង ប.ស.ស។

- **សម្រួលឲ្យមានភាពសាមញ្ញក្នុងការទទួលបានឯកសារផ្លូវច្បាប់ និងការទទួលបានសេវា៖** ធ្វើវិមជ្ឈការ និងសម្រួលឲ្យសាមញ្ញក្នុងការចេញឯកសារអត្តសញ្ញាណ និងឯកសារស្នាក់នៅសម្រាប់ជនចំណាកស្រុកពីតំបន់ជនបទមកតំបន់ទីក្រុង និងសម្រាប់កម្មករក្រៅប្រព័ន្ធ។ អនុញ្ញាតឱ្យមានការចេញប័ណ្ណសម្គាល់ជំនួស ឬបណ្ដោះអាសន្ន ដើម្បីទទួលបានគម្រោងកិច្ចគាំពារសង្គមដូចជា ប.ស.ស និងដាក់ចេញក្រុមចុះឈ្មោះ ប.ស.ស ចល័ត និងចំណុចផ្ដល់សេវាបណ្ដោះអាសន្នដោយផ្ទាល់នៅក្នុងសហគមន៍កម្មករអេតចាយ។

- **កែប្រែឡើងវិញនូវគោលនយោបាយគ្របដណ្ដប់និងការបង់ភាគទានសម្រាប់កិច្ចគាំពារសង្គម៖** អនុវត្តផែនការបង់ភាគទានចូល ប.ស.ស ដែលអាចបត់បែនបាននិងឧបត្ថម្ភធន ស្របតាមចំណូលនិងស្ថានភាពបំណុលរួមទាំងរយៈពេលអនុគ្រោះ និងគ្រោងការណ៍បង់តាមដំណាក់កាល។ អនុញ្ញាតឲ្យមេគ្រួសារដែលរកប្រាក់ចិញ្ចឹមគ្រួសារ ចុះឈ្មោះសមាជិកគ្រួសារ ជាពិសេសកុមារ មនុស្សចាស់ និងជនពិការ ដោយមិនគិតថ្លៃបន្ថែម។

- **បង្កើនជំនួយសង្គម និងជំនួយសង្គ្រោះបន្ទាន់៖** បង្កើតយន្តការគាំទ្រសង្គមដែលអាចទុកចិត្តបាន និងបន្តជាប់មិនដាច់ ក្នុងការផ្ដល់ជំនួយជាអាហារ ជំនួយផ្នែកវេជ្ជសាស្ត្រ ឧបករណ៍ថែទាំសុខភាព ការផ្គត់ផ្គង់សាលារៀន និងឧបករណ៍ការងារដូចជារទេះអេតចាយជាដើម។ ធានាបាននូវការគាំទ្រទាន់ពេលវេលា និងតាមតម្រូវការ ក្នុងអំឡុងពេលមានវិបត្តិ ដើម្បីកាត់បន្ថយសម្ពាធជីវភាពរស់នៅប្រចាំថ្ងៃ។

- **ទទួលស្គាល់កម្មករអេតចាយជាកម្មករ៖** ចាត់ថ្នាក់ជាផ្លូវការថាការងារអេតចាយនេះ ជាមុខរបរស្របតាមច្បាប់ ដោយមានមកជាមួយនូវសិទ្ធិការងារនិងកិច្ចគាំពារការងារ។ ធ្វើនិយ័តកម្មទៅលើភាពជាដៃគូរបស់និយោជក-កម្មករអេតចាយ ដើម្បីធានាបាននូវលក្ខខណ្ឌការងារដោយយុត្តិធម៌ ការប្រព្រឹត្តិស្មើភាពគ្នា និងការការពារតាមផ្លូវច្បាប់ឲ្យរួចផុតពីការកេងប្រវ័ញ្ច។

- **ពង្រីក និងកែលម្អលទ្ធភាពទទួលបានសេវាថែទាំសុខភាព៖** ពង្រឹងគុណភាព និងកេរ្តិ៍ឈ្មោះរបស់គ្លីនិកតាមមូលដ្ឋានដែលជាប់ពាក់ព័ន្ធនឹង ប.ស.ស ទន្ទឹមនឹងការកាត់បន្ថយការពឹងផ្អែកតែទៅលើមន្ទីរពេទ្យរដ្ឋ។ ដាក់

ពង្រាយគ្លីនិកសុខភាពចល័ត និងសេវាផ្សព្វផ្សាយចល័តសម្រាប់ការថែទាំភ្លាមៗ និងមានតម្លៃសមរម្យ។ ពង្រីកសេវាថែទាំសុខភាព និងការគ្របដណ្តប់របស់ ប.ស.ស ដល់មនុស្សចាស់ដែលមានអាយុលើសពី ៦០ ឆ្នាំ និងជនពិការតាមរយៈសេវាអាទិភាពដែលពោរពេញដោយឆន្ទៈខ្ពស់។

- **ការពារប្រឆាំងនឹងការរើសអើង អំពើហិង្សា និងការកេងប្រវ័ញ្ច៖** ដាក់ចេញយុទ្ធនាការប្រឆាំងការរើសអើង និងគំនិតផ្តួចផ្តើមបង្កើនការយល់ដឹងទូទាំងប្រទេស ដើម្បីកាត់បន្ថយការប្រមាថមើលងាយកម្មករអេតចាយ។ បង្កើតយន្តការបណ្តឹង និងយន្តការគាំទ្រដែលអាចបង្កលក្ខណៈងាយស្រួល ជាពិសេសសម្រាប់ស្ត្រី និងកុមារដែលប្រឈមមុខនឹងការរំលោភបំពាន ឬការបៀតបៀននៅតាមទីសាធារណៈ ក្នុងគ្រួសារ និងកន្លែងការងារ។

- **គាំទ្រស្ត្រី និងសមាជិកគ្រួសារដែលងាយរងគ្រោះ៖** ដាក់អនុវត្តអន្តរាគមន៍ដែលយល់ដឹងអំពីយេនឌ័រដែលផ្តល់អាទិភាពដល់សុវត្ថិភាពរបស់ស្ត្រីនៅក្នុងទីសាធារណៈនិងឯកជន។ ផ្តល់សេវាផ្លូវចិត្តសង្គម, លើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់សេវា និងការងារ ព្រមទាំងផ្តល់ការថែទាំកុមារ អាហារូបត្ថម្ភ និងការអប់រំដោយឥតគិតថ្លៃចំពោះកូនរបស់កម្មករអេតចាយ។ ផ្តល់អាទិភាពដល់សុវត្ថិភាពរបស់ស្ត្រីនៅក្នុងទីសាធារណៈ និងឯកជន ផ្តល់សេវាគាំទ្រផ្លូវចិត្តសង្គម និងលើកកម្ពស់សមភាពយេនឌ័រក្នុងការផ្តល់សេវា និងកម្មវិធីការងារតាមរយៈ អន្តរាគមន៍ដែលប្រកាន់យកយេនឌ័រ។

- **លើកកម្ពស់ការធ្វើពិពិធកម្មជីវភាពនិងការអភិវឌ្ឍន៍ជំនាញ៖** ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ, កម្មវិធីអក្ខរកម្ម និងការគាំទ្រការចាប់ផ្តើមអាជីវកម្មខ្នាតតូច ស្របតាមតម្រូវការរបស់កម្មករអេតចាយ ដែលអាចឱ្យពួកគេផ្លាស់ប្តូរទៅរកឱកាសការងារដែលមានសុវត្ថិភាព, ចំណូលខ្ពស់ និងស្ថិរភាពជាងមុន។

- **ពង្រឹងទំនុកចិត្តនិងសេវាកម្មថែទាំសុខភាពសហគមន៍៖** កសាងភាពជាដៃគូជាមួយគ្លីនិកនៅមូលដ្ឋានតាមរយៈការកែលម្អគុណភាពសេវាកម្ម តម្លៃសមរម្យ និងការជឿទុកចិត្តពីសហគមន៍។ លើកកម្ពស់ការប្រើប្រាស់សេវានៅមូលដ្ឋាន ដើម្បីកាត់បន្ថយភាពចង្អៀតណែនក្នុងមន្ទីរពេទ្យរដ្ឋ និងការពឹងផ្អែកលើឱសថស្ថានដែលគ្មាននិយ័តកម្មត្រឹមត្រូវ។

- **ពង្រឹង និងធ្វើឱ្យប្រព័ន្ធគាំពារសង្គមជាឌីជីថល៖** ធ្វើបណ្ណក្រីក្រជាឌីជីថល ដើម្បីឲ្យការផ្ទៀងផ្ទាត់កាន់តែងាយស្រួល និងធានាបាននូវការប្រាស្រ័យទាក់ទងច្បាស់លាស់ មានតម្លាភាព អំពីការតភ្ជាប់និងភាពញែកពីគ្នារវាងអត្ថប្រយោជន៍ ប.ស.ស និងបណ្ណក្រីក្រ ។ កែលម្អការសម្របសម្រួលរវាងរបបសន្តិសុខនានា ដើម្បីធានាថាកម្មករអេតចាយអាចទទួលបានសេវាយ៉ាងរលូនដោយគ្មានរបាំងការិយាធិបតេយ្យ។

# 03 សេចក្តីសន្និដ្ឋាន

ការសិក្សានេះបានរំលេចឡើងថា កម្មករអេតចាយគឺជាក្រុមទទួលបានអត្ថប្រយោជន៍តិចតួចនិងងាយរងគ្រោះ ដែលមានកម្រិតអប់រំទាប និងជីវភាពរស់នៅមិនទៀង។ អ្នកផ្តល់សម្ភាសភាគច្រើនមានការអប់រំកម្រិតបឋមសិក្សាតែប៉ុណ្ណោះ ដែលនេះជាការដាក់កំហិតចំពោះការទទួលបានព័ត៌មានអំពីគម្រោងគាំពារសង្គម ដូចជាបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) ជាដើម។ កម្មករអេតចាយ ច្រើនតែប្រឈមមុខនឹងឧបសគ្គក្នុងការទទួលបានការថែទាំសុខភាពផ្លូវការ ដោយពឹងផ្អែកលើការប្រើប្រាស់ថ្នាំដោយខ្លួនឯង ដោយសារបញ្ហាលទ្ធភាពនិងបញ្ហាមិនបង្កលក្ខណៈងាយស្រួល ហើយកាន់តែរាំងបន្ថែមទៀតដោយប្រាក់ចំណូលទាបនិងបំណុលខ្ពស់។ ការស្នើឲ្យមានការកែលម្អ រួមមាន រយៈពេលអនុគ្រោះសម្រាប់សេវា ប.ស.ស, ការរក្សាបានអត្ថប្រយោជន៍ក្នុងពេលអស់សុពលភាព និងការបង្កើតការផ្សព្វផ្សាយតាមសហគមន៍ដើម្បីបង្កើនការយល់ដឹង។

កម្មករអេតចាយក៏ជួបប្រទះបញ្ហាប្រឈមផ្នែកប្រជាសាស្ត្រ និងសេដ្ឋកិច្ចសំខាន់ៗមួយចំនួនដែរ។ អ្នកតបសម្ភាសជាច្រើនមានសមាជិកគ្រួសារច្រើន ដែលជាការដាក់បន្ទុកបន្ថែមលើហិរញ្ញវត្ថុគ្រួសារ ជាពិសេសដោយសារគម្រោងកញ្ចប់គ្រួសារដែលដាក់ចេញដោយ ប.ស.ស ។ ការទទួលបានសេវាថែទាំសុខភាព ជាពិសេសនៅមន្ទីរពេទ្យរដ្ឋ នៅតែមិនអាចទទួលបាន ដោយសារការចំណាយ និងពេលវេលាធ្វើដំណើរយូរ។ គម្រោងបង់ភាគទានបច្ចុប្បន្ន មិនទាន់មានបត់បែនបាន ហើយកម្មករអេតចាយដែលជាកម្មករក្រៅប្រព័ន្ធប្រឈមនឹងការលំបាកជាច្រើន ក្នុងការចូលរួមក្នុងកម្មវិធីសន្តិសុខសង្គមនេះ។ អនុសាសន៍ រួមមានការឧបត្ថម្ភធន, ការគ្របដណ្តប់សមាជិកគ្រួសារដោយមិនមានការចំណាយបន្ថែម និងការពង្រីកអត្ថប្រយោជន៍ដល់មនុស្សចាស់ និងអ្នកនៅក្នុងបន្ទុក។

បន្ថែមពីលើការលំបាកផ្នែកហិរញ្ញវត្ថុ កម្មករអេតចាយបានស៊ូទ្រាំនឹងការរំលោភបំពាន និងការរើសអើងរៀងរាល់ថ្ងៃ ជាពិសេសស្ត្រីដែលប្រឈមមុខនឹងភាពងាយរងគ្រោះខ្លាំងចំពោះអំពើហិង្សា និងការកេងប្រវ័ញ្ច។ កម្មករអេតចាយជាច្រើនមានអារម្មណ៍ថាត្រូវបានសង្គមផាត់ចេញ, ដោយសារការប្រឈមនឹងការបំពានពាក្យសម្តី ផ្លូវអារម្មណ៍ និងផ្លូវកាយ ពីពលរដ្ឋនិងអាជ្ញាធរ។ ការសិក្សានេះក៏ចង្អុលបង្ហាញអំពីកង្វះប្រព័ន្ធគាំទ្រសង្គម ដោយកុមារត្រូវបានប្រឈមនឹងបរិស្ថានអសុវត្ថិភាព និងការបដិសេធក្នុងការទទួលបានការអប់រំ។ មានការទាមទារច្បាស់លាស់ឲ្យមានការទទួលស្គាល់កម្មករអេតចាយជាផ្លូវការថាជាកម្មករ ដែលមានសិទ្ធិទទួលបានសន្តិសុខសង្គម, ការការពារផ្លូវច្បាប់ និងការទទួលបានឯកសារអត្តសញ្ញាណ។ វិសមភាពយេនឌ័រកាន់តែធ្វើឱ្យការតស៊ូរបស់ពួកគេកាន់តែពិបាកធ្ងន់ធ្ងរឡើង ដោយស្ត្រីត្រូវប្រឈមមុខនឹងការងារថែទាំគ្មានកម្រៃនិងអំពើហិង្សាក្នុងគ្រួសារ។ ការសិក្សានេះ អំពាវនាវឱ្យមានប្រព័ន្ធគាំពារសង្គមដែលអាចបត់បែនបាន និងប្រកបដោយបរិយាបន្ន ដើម្បីដោះស្រាយភាពងាយរងគ្រោះទាំងនេះ។

# ករណីសិក្សាទី១

## ស្រីល័ក្ខ

## ជីវិតតស៊ូ កម្លាំងចិត្ត និងក្ដីសង្ឃឹម របស់កម្មករអេតចាយ

### ដំណើររបស់អ្នកម្ដាយវ័យក្មេងមួយរូប

ស្រីល័ក្ខ អាយុ ២៧ ឆ្នាំ ជាម្ដាយមួយរូប ដែលបានផ្លាស់ពីខេត្តសៀមរាបកាលពី ៨ ឆ្នាំមុន មករស់នៅក្រុងភ្នំពេញជាមួយកូនប្រុសអាយុ ៧ ឆ្នាំដែលកំពុងរៀនថ្នាក់ទី ២ នៅសាលាបឋមសិក្សាមួយក្នុងរាជធានីភ្នំពេញ។ បច្ចុប្បន្ននេះ ស្រីល័ក្ខកំពុងពពោះកូនទី២ ក្នុងខែទី២ ហើយស្រីល័ក្ខបន្តប្រឈមមុខនឹងការលំបាកជារៀងរាល់ថ្ងៃ ខណៈនាងសង្ឃឹមថា កូនរបស់នាងនឹងមានអនាគតល្អប្រសើរ។

### ជីវិតរើសអេតចាយ



ស្រីល័ក្ខបានធ្វើការជាកម្មករអេតចាយអស់រយៈពេលប្រាំបីឆ្នាំមកហើយ នេះជាការងារដែលនាងបានចាប់ផ្ដើមធ្វើដំបូងជាមួយម្ដាយក្មេករបស់គាត់។ រាល់ថ្ងៃ ស្រីល័ក្ខចាប់ផ្ដើមធ្វើការនៅម៉ោង ៦:០០ ឬ ៦:៣០ ព្រឹក ដោយធ្វើដំណើរប្រហែល ៣០ នាទីផ្ទះជួលនៅក្នុងសង្កាត់បឹងសាឡាង ទៅកាន់ម្ដុំក្បែរផ្សារអូឬស្សី គឺនៅជិតកន្លែងដែលកូនប្រុសរបស់នាងទៅរៀន។ ការធ្វើបែបនេះ អនុញ្ញាតឱ្យស្រីល័ក្ខអាចនៅជិតកូនប្រុស នៅពេលស្រីល័ក្ខធ្វើការ។

ស្រីល័ក្ខស្នាក់នៅផ្ទះជួលមួយ ជាមួយគ្រួសាររបស់បងថ្លៃដែលប្រកបរបរជាកម្មករអេតចាយដូចគ្នា សរុបមានគ្នា ៦នាក់រស់នៅក្នុងផ្ទះជួលជាមួយគ្នានេះ។ ពួកគេចែកគ្នាចេញថ្លៃជួលម្នាក់ពាក់កណ្ដាល សម្រាប់ថ្លៃឈ្នួលប្រចាំខែចំនួន ៧០ ដុល្លារ ដោយក្នុងម្នាក់ៗបានចូលរួមចំណែក ៣៥ ដុល្លារ។ ភាគច្រើន ស្រីល័ក្ខ រើសសំរាមតាមដងផ្លូវ។ មានម្ដងម្កាល ប្រសិនបើនាងមានប្រាក់បន្ថែមបន្តិចបន្តួច នាងទិញបណ្ដើរ រើសបណ្ដើរ។ នាងមានរទេះសំរាមចំនួនពីរ ដែលមួយនោះមានតម្លៃប្រហែល ១៥០ ដុល្លារ ជារបស់ម្ដាយក្មេករបស់នាងដែលបានស្លាប់នាពេលថ្មីៗកន្លងមកនេះ។

### ការរស់ក្នុងជីវិតមួយដែលមានចំណូលតិចតួច

បន្ទាប់ពីកូនប្រុសនាងចេញពីរៀនវិញ រៀងរាល់ល្ងាច ពួកគេត្រឡប់ទៅផ្ទះជួលវិញដើម្បីរៀបអេតចាយប្រមូលបានមកដាក់តាមប្រភេទ និងយកទៅលក់រាល់ថ្ងៃ។ ក្រោយពេលបាយល្ងាចរួច ពួកគេចេញទៅរើសអេតចាយម្ដងទៀតរហូតដល់យប់ជ្រៅទើបត្រឡប់មកផ្ទះវិញ។ កូនប្រុសវ័យ៧ឆ្នាំរបស់នាង តែងតែទៅជាមួយនាង ហើយជួយនាងរើសអេតចាយ រហូតដល់អស់កម្លាំង ទើបឡើងទៅសម្រាកនៅក្នុងរទេះ។

ជាមធ្យម ស្រីល័ក្ខ រកប្រាក់បានប្រហែល ២០.០០០ រៀល ក្នុងមួយថ្ងៃ ដែលស្ទើរតែមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ថ្លៃជួលផ្ទះ ថ្លៃអាហារ និងតម្រូវការចាំបាច់នានាផង។ អាហាររបស់គាត់ គឺជាអាហារធម្មតាៗនិងមានបរិមាណតិច ដែលត្រូវចំណាយប្រហែល ៣.០០០ រៀល ក្នុងមួយពេល ដែលភាគច្រើនមានតែបាយរួមជាមួយនឹងអាហារបន្តិចបន្តួចប៉ុណ្ណោះ។ ស្រីល័ក្ខ ហូបតែបាយនិងម្ហូបដែលនៅសល់បន្ទាប់ពីកូនប្រុសហូបឆ្អែតប៉ុណ្ណោះ។ ប្រសិនបើកូនប្រុសគាត់ហូបអស់ គាត់ត្រូវរង់ចាំដល់ពេលអាហារបន្ទាប់ ឬស្វែងរកអាហារដែលអាចគេបោះចោលតាមផ្លូវ ប៉ុន្តែនៅអាចបរិភោគបាន។

ពេលមានពិធីបុណ្យទានតាមសាសនា ឬពិធីមង្គលការ កម្មករអេតចាយ ដូចស្រីល័ក្ខ ពឹងផ្អែកលើអាហារដែលសល់ពីភ្ញៀវក្នុងពិធីទាំងនោះ។ ឱកាសទាំងនេះអនុញ្ញាតឱ្យពួកគេញុាំបានឆ្អែត ហើយជួនកាលអាចរក្សាទុកអាហារខ្លះសម្រាប់ថ្ងៃបន្ទាប់ទៀតផង។ ស្រីល័ក្ខតែងស្ម័គ្រចិត្តជួយសម្អាតរោងពិធី ក្រោយកម្មវិធីបានបញ្ចប់ ដោយសង្ឃឹមថាម្ចាស់ពិធីនឹងផ្តល់អាហារឲ្យមួយចំនួន ឬអ្វីបន្តិចបន្តួចជាសគុណពីម្ចាស់ផ្ទះដែលខ្លួនបានជួយ។

## ការតស៊ូចំពោះការចំណាយលើការសិក្សារបស់កូនប្រុស

ទោះបីស្ថិតក្នុងស្ថានភាពលំបាកយ៉ាងណាក៏ដោយ ក៏ស្រីល័ក្ខនៅតែផ្តល់អាទិភាពដល់ការសិក្សារបស់កូនប្រុសនាងជានិច្ច។ ពេលមានលុយ ស្រីលក័ក្ខឱ្យកូនគាត់ ១០០០-២០០០ រៀល យកទៅសាលារៀន។ ប៉ុន្តែ យ៉ាងណាមិញ មានពេលជាច្រើនដែលស្រីល័ក្ខមិនមានលុយនៅជាប់ខ្លួននោះទេ ហើយក្នុងស្ថានភាពបែបនេះ ស្រីល័ក្ខត្រូវពន្យល់ប្រាប់កូនប្រុសរបស់នាងអំពីការមិនមានលុយឱ្យ មុននឹងបញ្ចុះបញ្ចូលកូនឱ្យទៅរៀនដោយគ្មានលុយពីម្តាយ។ ដោយសារតែបែបនេះ កូនប្រុសរបស់ស្រីល័ក្ខបានគេចសាលាជាច្រើនដង ដោយសារភាពខ្មាសអៀន នៅពេលដែលមិត្តរួមថ្នាក់ដឹងថាគាត់មិនមានលុយទៅរៀន ដោយសារម្តាយរបស់គាត់ជាកម្មករអេតចាយ។

ការចំណាយបន្ថែមសម្រាប់ការរៀននៅសាលា គឺជាបន្ទុកមួយផ្សេងទៀតសម្រាប់ស្រីល័ក្ខ។ ការរៀនគួរបន្ថែម តម្រូវឱ្យបង់ប្រាក់ប្រចាំខែចំនួន ៤០.០០០ រៀលក្នុងមួយខែ។ ដោយសារស្រីល័ក្ខមិនអាចបង់ថ្លៃរៀនគួរឱ្យបានទៀងទាត់នោះ ស្រីល័ក្ខបានកត់សម្គាល់ឃើញថា នៅពេលបានបង់ប្រាក់រៀនគួរប្រចាំខែ កូនប្រុសគាត់តែងមានកិច្ចការផ្ទះពីសាលា ប៉ុន្តែសម្រាប់ខែណាដែលគាត់មិនបានបង់លុយនោះទេ កូនប្រុសគាត់មិនសូវមានកិច្ចការផ្ទះដែលគ្រូដាក់ឱ្យនោះទេ។ កូនប្រុសគាត់ត្រូវបង់លុយថ្លៃក្រដាសប្រឡងប្រចាំខែនីមួយ ជាមធ្យម ២០០០ រៀល ក្នុងមួយខែទៀតផង។ ដោយភាពអស់សង្ឃឹម ស្រីល័ក្ខធ្លាប់បានសុំឱ្យគ្រូលើកលែងកុំឱ្យកូនប្រុសរបស់គាត់បង់លុយទាំងនេះ ដោយពន្យល់ពីការងាររបស់នាងជាកម្មករអេតចាយ និងមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង់ប្រាក់ទាំងនេះទេ។ គ្រូបាននិយាយថា គាត់អាចលើកលែងបាន លុះត្រាតែមានបណ្ណក្រីក្រ ប៉ុន្តែស្រីល័ក្ខគ្មានបណ្ណក្រីក្រនេះទេ។

## ការតស៊ូប្រឹងប្រែងសម្រាប់សេវាចាំបាច់សំខាន់ៗ

ស្រីល័ក្ខត្រូវចំណាយថ្លៃទឹក ភ្លើង ក្នុងចន្លោះពី ២០.០០០ ទៅ ៣០,០០០ រៀល ក្នុងមួយខែៗ។ នៅពេលមិនអាចប្រាក់គ្រប់គ្រាន់ទេនោះ ស្រីល័ក្ខត្រូវខ្ចីពីអ្នកនៅក្នុងផ្ទះជួលជាមួយគ្នានោះ ហើយសងត្រឡប់ទៅវិញដោយត្រូវបង់ការប្រាក់បន្តិចបន្តួចបន្ថែមពីលើប្រាក់ដែលខ្ចីនោះ។ ស្រីល័ក្ខបានស្នើសុំប័ណ្ណក្រីក្រពីអាជ្ញាធរមូលដ្ឋានម្តងហើយម្តងទៀត ប៉ុន្តែត្រូវបានបដិសេធជាបន្តបន្ទាប់ បើទោះបីជាស្រីល័ក្ខបានឃើញដោយផ្ទាល់ភ្នែកថាក្រុមគ្រួសារ

ដែលមានប្រាក់ចំណូលស្ថិរភាព និងអាជីវកម្មមួយចំនួន ទទួលបានអត្ថប្រយោជន៍នៃបណ្ណក្រីក្រ ដែលអ្នកក្រីក្រដូច ជារូបនាង ត្រូវការយ៉ាងខ្លាំងទៅវិញ។

ការបាត់បង់ឯកសារអត្តសញ្ញាណបណ្ណដើម បានបន្ថែមឧបសគ្គមួយទៀតដល់នាង ដែលរារាំងស្រីល័ក្ខពី ការចុះឈ្មោះក្នុងបញ្ជីបេឡាជាតិសន្តិសុខសង្គម (ប.ស.ស)។ ស្រីល័ក្ខមិនអាចទទួលបានជំនួយថែទាំសុខភាព ឬ ចុះឈ្មោះដើម្បីទទួលបានអត្ថប្រយោជន៍មាតុភាព ដោយគ្មានបណ្ណណាមួយនេះឡើយ។

## ការមាក់ងាយ ការរើសអើង និងភាពឯកោក្នុងសង្គម

ស្រីល័ក្ខ និងកូនប្រុស តែងប្រឈមមុខនឹងការមាក់ងាយ និងការរើសអើង។ អ្នកជិតខាងបានហាមកូនរបស់ ពួកគេ កុំឱ្យមកលេងជាមួយកូនប្រុសរបស់ស្រីល័ក្ខ ពីព្រោះកូនប្រុសរបស់គាត់ ជាកូនអ្នករើសអេតចាយ។ ស្រីល័ក្ខ តែងសម្គាល់ឃើញមនុស្សម្នានាំគ្នាយកដល់ខ្ទប់ច្រមុះពេលដើរកាត់មុខនាង ដោយចាត់ទុកជាមនុស្សកខ្វក់។ ស្រី ល័ក្ខសម្គាល់ឃើញដែរថា នៅពេលមានការកកស្ទះចរាចរណ៍នៅពេលដែលនាងកំពុងអូសរទេះអេតចាយនោះ ក៏ នាងធ្លាប់ទទួលការការស្តីបន្ទោសពីអ្នកធ្វើដំណើរឆ្លងកាត់ថា មកពីនាងអូសរទេះអេតចាយសំពីងសំពោងទើបធ្វើឱ្យ ស្ទះផ្លូវបែបនោះ។

កូនប្រុសរបស់នាងដែលបានដឹងរឿងឈឺចាប់បែបនេះច្បាស់ បានប្រាប់ម្តាយរបស់គាត់ថា គាត់ចង់ឈប់ រៀនដើម្បីគេចចេញពីការធ្វើបាបសើចចំអក និងវិនិច្ឆ័យមកលើរូបគាត់បែបនេះ។ គាត់ធ្លាប់បង្ហើបថា គ្រូបានប្រាប់ គាត់ឱ្យរំលឹកម្តាយទៅបង់ប្រាក់ជាមុនសិន ប្រសិនបើចង់ឱ្យកូនមានកិច្ចការផ្ទះពីសាលាមកនោះ។

## ការបាត់បង់មនុស្សជាទីស្រឡាញ់

នៅដើមឆ្នាំ២០២៥ សោកនាដកម្មមួយបានវាយប្រហារមកលើគ្រួសាររបស់ស្រីល័ក្ខ នៅពេលដែលម្តាយ ក្មេករបស់នាង ដែលជាកម្មកររអេតចាយនិងជាអ្នកណែនាំស្រីល័ក្ខមកធ្វើជាកម្មកររអេតចាយដែរនោះ បានទទួល មរណភាពក្នុងកម្មវិធីសប្បុរសធម៌ចែកអំណោយមុនថ្ងៃចូលឆ្នាំចិន។ ខណៈពេលដែលមនុស្សដ៏ច្រើនកុះករកំពុងរង់ ចាំទទួលអំណោយពីឧកញ៉ាម្នាក់នោះ ម្តាយក្មេករបស់ស្រីល័ក្ខបានដួលនិងត្រូវគេជាន់ស្លាប់ ហើយកូនប្រុសរបស់ នាងក៏បានរងរបួសជើងដែរ។ ក្រោយហេតុការណ៍នោះ គ្រួសាររបស់ស្រីល័ក្ខ បានទទួលអំណោយពីសប្បុរសជន ផ្សេងៗ និងទទួលបានការគាំទ្រពីសមាគមសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អាយឌា) ក្នុងនាមជាសមាជិករបស់សមាគម។ ប៉ុន្តែ នាងទទួលបានចំណែកតិចតួចណាស់ ដោយនៅពេលនោះ ជំនួយភាគច្រើនបានទៅកូនប្រុសច្បងរបស់ម្តាយ ក្មេកស្រីល័ក្ខ។

## កង្វល់ខ្លាំងបំផុតរបស់ម្តាយ



ការព្រួយបារម្ភខ្លាំងបំផុតរបស់ស្រីល័ក្ខ គឺការអប់រំនិងអនាគតរបស់កូនប្រុសនាង។ ចាប់ពីថ្ងៃចូលរៀនដំបូង រហូតមកដល់ពេលនេះ កូនប្រុសរបស់នាងមានអាវពណ៌ស សម្រាប់ពាក់ទៅរៀនតែមួយគត់។ ស្រីល័ក្ខបោកសម្អាតអាវនេះជារៀងរាល់យប់ ដើម្បីឱ្យកូនរបស់គាត់អាចពាក់បានវិញនៅថ្ងៃបន្ទាប់។ បច្ចុប្បន្ននេះ អាវនេះរហែកមានប្រហោងនៅលើ កអាវផ្នែកខាងក្រោយ ដែលជាសញ្ញាបង្ហាញឱ្យឃើញនូវភាពលំបាកលំបិនរបស់ពួកគេ។

ស្រីល័ក្ខមានក្តីស្រមៃចង់ចុះឈ្មោះកូនប្រុសចូលរៀនភាសាអង់គ្លេស ដែលត្រូវបង់ថ្លៃសិក្សាចំនួន ១០ ដុល្លារក្នុងមួយខែ ប៉ុន្តែនាងមិនអាចរកលុយបង់បានទេ។ ការមានផ្ទៃពោះកូនទីពីរនេះ ក៏ធ្វើឱ្យស្រីល័ក្ខមានការបារម្ភអន្ទះអន្ទែងក្នុងចិត្តឥតឈប់ឈរដែរ។ ប្រសិនបើគ្មានបណ្ណក្រីក្រនេះទេ នាងមិនអាចបង់ប្រាក់សម្រាប់ការពិនិត្យផ្ទៃពោះបានជាប្រចាំទេ និងមានក្តីព្រួយបារម្ភអំពីការរកលុយសម្រាប់ការសម្រាលនៅពេលគ្រប់ខែទៀតផង។ ស្រីល័ក្ខសង្ឃឹមថានឹងចុះឈ្មោះ ប.ស.ស បានទោះត្រូវបង់ភាគទានប្រចាំខែចំនួន ១៥៦០០ រៀល ដែលជាចំនួនទឹកប្រាក់ដែលនាងមិនប្រាកដថានាងអាចបង់បានជាប់លាប់ក៏ដោយ ក៏ស្រីល័ក្ខសុខចិត្តខំប្រឹងប្រែងរកមកបង់ ប្រសិនបើអាចធានាដល់ការសម្រាលកូនប្រកបដោយសុវត្ថិភាពនោះ។

នៅពេលទៅពិនិត្យផ្ទៃពោះលើកដំបូង ស្រីល័ក្ខបានចំណាយប្រាក់ប្រហែល ៥០.០០០ រៀល ប៉ុន្តែឥឡូវនេះនាងខ្លាចថានឹងមិនអាចរកប្រាក់បានសម្រាប់ការទៅពិនិត្យម្តងទៀតនោះទេ។ ស្រីល័ក្ខ បានសារភាពថា សូម្បីតែពេលមានផ្ទៃពោះនេះ ក៏មានពេលខ្លះនាងត្រូវខានហូបអាហារ ឬមិនហ៊ានទិញទឹកហូបដែរ ដោយសារខ្វះលុយ។ នាងកម្រមានលុយ ១០០.០០០ រៀល ក្នុងខ្លួនណាស់ ហើយរាល់ពេលគិតដល់ការត្រូវចំណាយប្រាក់សម្រាប់ការសម្រាល តែងតែធ្វើឱ្យស្រីល័ក្ខមានភាពភ័យខ្លាចណាស់។

## ការទប់ទល់នឹងជំងឺ

នៅពេលឈឺ ស្រីល័ក្ខលេបតែថ្នាំប៉ារ៉ាសេតាម៉ុលប៉ុណ្ណោះ។ នាងទៅរកឱសថស្ថានផ្សំថ្នាំ តែនៅពេលដែលឈឺខ្លាំងរហូតដល់ដើរជើងជោងខ្លាំងប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ស្រីល័ក្ខតែងផ្តល់អាទិភាពលើការចំណាយការថ្លៃសិក្សារបស់កូនប្រុស ជាងសុខភាពរបស់ខ្លួន។ ជាញឹកញយ នៅពេលដែលនាងមិនមានលុយឱ្យកូនទៅសាលារៀននោះ អ្នកជិតខាងដែលមានចិត្តល្អ បានហុចលុយឱ្យបន្តិចបន្តួច ដើម្បីឱ្យកូនគាត់ទៅរៀន។

## ការគ្មានជំនឿ និងភាពអយុត្តិធម៌

អ្វីដែលស្រីល័ក្ខអន្ទះអន្ទែងខកចិត្តបំផុតនោះ គឺការចែកជំនួយដោយអយុត្តិធម៌។ នាងបានឃើញម្ចាស់ហាងគុយទាវ និងអ្នកលក់ម៉ូតូនៅជុំវិញតំបន់ដែលនាងធ្វើការ គឺអ្នកដែលមានប្រាក់ចំណូលមានស្ថិរភាព ទទួលបានបណ្ណក្រីក្រ ខណៈដែលមនុស្សដូចនាងដែលជួបការលំបាកជារៀងរាល់ថ្ងៃ ត្រូវបានគេទុកចោលមិនអើពើទៅវិញ។ ភាពអយុត្តិធម៌បែបនេះ មានភាពឃោរឃៅដល់ចំណុចដែលស្រីល័ក្ខគិតមិនយល់ទាល់តែសោះ។

## ការគាំទ្រពីសមាគមអាយឌា

តាមរយៈភាពជាសមាជិកភាពរបស់សមាគមអាយឌា ដែលជាសមាគមក្នុងស្រុកមួយគាំទ្រកម្មករអេតចាយ និងកម្មករសេដ្ឋកិច្ចក្រៅប្រព័ន្ធផ្សេងទៀតនោះ ស្រីល័ក្ខបានទទួលចំណេះដឹងដ៏មានតម្លៃអំពីសិទ្ធិរបស់នាងក្នុងនាមជាពលរដ្ឋ សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ សេរីភាព និងលទ្ធភាពទទួលបានការការពារសង្គមជាមូលដ្ឋាន។ នាងបានដឹងអំពីជំនួយនិងសេវាកម្មដែលនាងមានសិទ្ធិទទួលបាន រួមទាំងអត្ថប្រយោជន៍នៃបណ្ណក្រីក្រ និង ប.ស.ស ទោះបីជានាងមិនទាន់ទទួលបានក៏ដោយ។

ទោះបីជាស្រីល័ក្ខជាសមាជិកសមាគមអាយឌាក៏ដោយ ក៏ស្រីល័ក្ខមានការលំបាកក្នុងចូលរួមសកម្មភាពឱ្យបានពេញលេញដែរ។ បន្ទុកហិរញ្ញវត្ថុសម្រាប់ការរស់រានប្រចាំថ្ងៃ ធ្វើឱ្យនាងមិនអាចមានលទ្ធភាពទិញធ្វើដំណើរទៅចូលរួមកិច្ចប្រជុំ និងសិក្ខាសាលានៅការិយាល័យសមាគមអាយឌាបានគ្រប់ពេលដែលត្រូវបានអញ្ជើញនោះទេ។ ទោះបីជាសមាគមបានផ្តល់ការគាំទ្រនិងព័ត៌មានសំខាន់ៗដល់នាងក៏ដោយ ក៏ភាពក្រីក្រនៅតែរាំងស្រីល័ក្ខក្នុងការបន្តទទួលបានធនធានទាំងឡាយនោះដែរ។

## ស្មារតីដែលមានភាពធន់

ទោះជាជួបការលំបាកច្រើនយ៉ាងនេះក្តី ក៏ស្រីល័ក្ខ នៅតែប្តេជ្ញាចិត្តចំពោះអនាគតកូនប្រុសរបស់នាង ហើយមិនព្រមបោះបង់ក្តីសង្ឃឹមមួយនេះឡើយ។ រឿងរ៉ាវរបស់ស្រីល័ក្ខ បង្ហាញអំពីភាពអត់ធ្មត់ ទឹកចិត្តស្រឡាញ់ និងការតាំងចិត្តក្នុងការផ្តល់ជីវិតប្រសើរមួយ សម្រាប់កូនរបស់នាង មិនថាមានរឿងអ្វីកើតឡើងចំពោះនាងនោះទេ។

*«ទោះជីវិតស្ថិតក្នុងភាពលំបាកបំផុតក៏ដោយ ក៏ខ្ញុំត្រូវតែមានក្តីសង្ឃឹមក្នុងចិត្តជានិច្ច ដើម្បីកូនរបស់ខ្ញុំ»។*

# ករណីសិក្សាទី២

## អ្នកស្រី រដ្ឋានី

### កម្មករអេតចាយក្រៅប្រព័ន្ធម្នាក់នៅភ្នំពេញ

*ប្ដូរឈ្មោះពិតដើម្បីការពារអត្តសញ្ញាណ

### សាវតានិងស្ថានភាពរស់នៅ



អ្នកស្រីរដ្ឋានី បានដើររើសសំរាមនៅភ្នំពេញ តាំងពីឆ្នាំ១៩៩៨ មកដល់ពេលនេះគាត់មានអាយុ៥៤ ឆ្នាំហើយ។ អ្នកស្រីទទួលបានកន្លែងស្នាក់នៅដោយឥត គិតថ្លៃនៅដេប៉ូប្រមូលទិញអេតចាយ (យឿ) ដែលគាត់ រស់នៅជាមួយប្អូនស្រីភ្លោះ និងកូនស្រីម្នាក់អាយុ ១៩ ឆ្នាំ។ នៅយឿនោះ មានកម្មករអេតចាយប្រហែល ២០ នាក់រស់នៅក្នុងបរិវេណតែមួយ ដោយម្នាក់ៗមានបន្ទប់ តូចមួយទំហំប្រហែល ២ ម៉ែត្រ បួនជ្រុង។ អ្នកស្រីរដ្ឋានី និងប្អូនស្រីភ្លោះរបស់គាត់ មានបញ្ហាលំបាកខ្លាំងក្នុងការ ស្ដាប់ ចាប់តាំងពីទទួលរងគ្រោះថ្នាក់ចរាចរណ៍នៅស្រុក កំណើតក្នុងខេត្តព្រៃវែង តាំងពីមុនពេលគាត់ចាប់ផ្ដើមធ្វើការជាកម្មករអេតចាយនេះមកម្ល៉េះ។ ដោយសារតែមាន បញ្ហាក្នុងការស្ដាប់នេះ ជួនកាលគាត់បាត់បង់ឱកាសក្នុងការទិញ ឬប្រមូលសំរាម ព្រោះស្ដាប់មិនឮពេលគេស្រែក ហៅគាត់។

### ការរៀបចំចាត់ចែងនៅតាមយឿ

ជាថ្នូរនឹងការស្នាក់នៅដោយមិនគិតថ្លៃ អ្នកស្រីរដ្ឋានី ត្រូវលក់អេតចាយទាំងអស់ដែលប្រមូលឬទិញបាន ឱ្យ ម្ចាស់ដេប៉ូដែលផ្ដល់កន្លែងស្នាក់នៅឱ្យគាត់តែម្នាក់គត់។ ម្ចាស់យឿក៏ឱ្យគាត់ខ្ចីរទេះរុញសម្រាប់ដាក់អេតចាយដែរ។ ទោះបីជាគ្មានកិច្ចសន្យាលាយលក្ខណ៍អក្សរក៏ដោយ ក៏គាត់មិនហ៊ានលក់អេតចាយទាំងឡាយឲ្យយឿផ្សេងដែរ ពីព្រោះថា បើម្ចាស់យឿដឹងថាគាត់លក់អេតចាយឱ្យអ្នកផ្សេង គាត់អាចប្រថុយនឹងការបាត់បង់កន្លែងស្នាក់នៅ មិន មានរទេះរិញ និងមិនអាចខ្ចីប្រាក់ពីម្ចាស់យឿទៀតបានទេ។

### ទម្លាប់ការងារនិងប្រាក់ចំណូលប្រចាំថ្ងៃ

រៀងរាល់ព្រឹកម៉ោងប្រហែល ៦:៣០នាទី អ្នកស្រីរដ្ឋានី ចេញពីយឿដើម្បីទៅធ្វើការ បន្ទាប់ពីខ្ចីលុយពីម្ចាស់ យឿចំនួន ១៥០,០០០រៀល (ប្រហែល ៣៧.៥០ ដុល្លារ) ដើម្បីទិញអេតចាយ គួបផ្សំជាមួយនឹងការរើសអេតចាយ

តាមពេលដែលប្រទះឃើញ។ ប្រសិនបើបានអេតចាយពេញរទេះត្រឹមពេលថ្ងៃត្រង់ គាត់ត្រឡប់មកយឿវិញមួយជើងសិន ដើម្បីដាក់អេតចាយចុះ មុនពេលចាប់ផ្តើមទៅរកនៅពេលរសៀលទៀត។ បើមិនពេញរទេះត្រឹមថ្ងៃត្រង់ទេ គាត់នៅបន្តដើររក ហើយជាធម្មតាត្រឡប់ទៅផ្ទះវិញនៅចន្លោះម៉ោង ៥:០០ ទៅ ៦:០០ ល្ងាច។ ចំនួនទឹកប្រាក់ដែលគាត់ចំណាយលើការទិញអេតចាយ មានការប្រែប្រួលមិនទៀងទាត់ទេ។ ជាមធ្យម គាត់ចំណាយប្រហែល ៥ ម៉ឺនរៀលសម្រាប់ទិញអេតចាយ។ ប្រាក់ចំណេញប្រចាំថ្ងៃដែលបានមកពីការទិញនិងរើសអេតចាយ ក្រោយពេលកាត់កងចំណាយថ្លៃទិញរួចមក មានចន្លោះពី ៥០០០ រៀលដល់ ៣០.០០០ រៀលក្នុងមួយថ្ងៃ ដែលភាគច្រើនបំផុតបានចន្លោះពី ១០.០០០ រៀល ទៅ ២០.០០០ រៀល។

## អសន្តិសុខស្បៀង និងការអប់រំសម្រាប់កូនស្រី

រៀងរាល់ព្រឹក អ្នកស្រីរដ្ឋានីបានយកលុយដែលខ្ចីពីម្ចាស់យឿ ឱ្យកូនស្រីរបស់គាត់ចំនួន ១៥.០០០ រៀល (៣.៧៥ ដុល្លារ) សម្រាប់ទៅរៀន ជាហេតុធ្វើឱ្យគាត់តែងតែមិនហូបអាហារពេលព្រឹក ព្រោះគាត់គិតថាមិនអាចចាយលុយនេះបានទៀតទេ។ សម្រាប់អាហារថ្ងៃត្រង់និងអាហារពេលល្ងាច សម្រាប់គាតនិងកូនស្រី គាត់ត្រូវចំណាយប្រហែល ១០.០០០ រៀល (ប្រមាណ ២,៥០ ដុល្លារអាមេរិក) ក្នុងមួយថ្ងៃ។ អាហារមួយចំនួនបានទទួលពីមនុស្សម្នានានានៅកន្លែងដែលគាត់ដើររកអេតចាយ ជាពិសេសនៅជុំវិញផ្សារដែលមានមនុស្សច្រើន។ ទោះបីជាជួបការលំបាកផ្នែកហិរញ្ញវត្ថុក៏ដោយ ក៏គាត់ខិតខំចំណាយសម្រាប់ការបង់ថ្លៃរៀនភាសាបរទេសជាប្រចាំខែសម្រាប់កូនស្រីរបស់គាត់បន្ថែមទៀតដែរ។ អ្នកស្រីរដ្ឋានី មានកូនបីនាក់។ កូនច្បងទាំងពីរនាក់បានរៀបការនិងចេញទៅរស់នៅដាច់ដោយឡែកជាមួយគ្រួសាររៀងៗខ្លួន ដោយនៅសល់តែកូនពៅអាយុ ១៩ ឆ្នាំនេះ រស់នៅក្នុងយឿជាមួយគ្នា។

## ការរើសអើង អារម្មណ៍ឈឺចាប់ និងភាពជាម្តាយ

អ្នកស្រីរដ្ឋានីនិងប្អូនស្រីភ្លោះរបស់គាត់ ត្រូវប្រឈមនឹងការរើសអើងដោយសារតែខ្លួនជាកម្មករអេតចាយ។ គាត់តែងជួបមនុស្សដែលមើលងាយ និងមិនគោរពការងាររបស់គាត់ជារឿយៗខ្លាំងណាស់ ហើយដែលគាត់បានទទួលយកថាជារឿងដែលជៀសមិនរួចទៅហើយ។ បញ្ហាពិបាកស្តាប់របស់គាត់និងរបស់ប្អូនស្រីភ្លោះរបស់គាត់ ក៏បានធ្វើឱ្យពួកគេក្លាយជាគោលដៅនៃការចំអក និងការលេងសើចពីមនុស្សដែលរស់នៅក្នុងយឿជាមួយគ្នានេះដែរ។

គាត់ជឿថា ការរើសអើងនេះបានប៉ះពាល់យ៉ាងខ្លាំងដល់កូនស្រីរបស់គាត់ដែលកំពុងស្ថិតក្នុងវ័យសិក្សា ដែលជារឿយៗ ដោយសារតែគេប្រមាថមើលងាយម្តាយ។ រឿងនេះ ធ្វើឲ្យអ្នកស្រីរដ្ឋានី ឈឺចិត្តខ្លាំងណាស់។ អ្នកស្រីធ្លាប់គិតចង់ធ្វើអត្តឃាតជាញឹកញាប់ ពីព្រោះតែការឈឺចាប់ដែលកូនស្រីរបស់ខ្លួនទទួលរងដោយសារតែស្ថានភាពរបស់ម្តាយ។ ប៉ុន្តែទន្ទឹមគ្នានេះ ក្តីស្រលាញ់និងការអាណិតអាសូរចំពោះកូនស្រី បានផ្តល់កម្លាំងចិត្តនិងក្តីសង្ឃឹមឱ្យគាត់បន្តការតស៊ូរបស់ខ្លួន។ អ្នកស្រីបានរំលឹកថា នៅពេលកូនស្រីគាត់ទើបតែកើតបាន ១៥ថ្ងៃ គាត់គ្មានជម្រើសអ្វីក្រៅពីដាក់ទារិកាដ៏កំសត់នោះនៅក្នុងរទេះអេតចាយ ទៅជាមួយគាត់ដើម្បីរកអេតចាយនោះទេ។

## ជំងឺពុំរ៉ៃ និងបំណុលកើនឡើង

កន្លងមក អ្នកស្រីរដ្ឋានីបានខ្ចីប្រាក់ចំនួន ៤.០០០.០០០រៀល (ប្រហែល ១,០០០ដុល្លារអាមេរិច) ដើម្បី

ចំណាយលើថ្លៃព្យាបាលកូនស្រីរបស់គាត់ដែលមានជំងឺគ្រុនឈាម ដោយសារកូនស្រីរបស់គាត់មិនមានការធានារ៉ាប់រងពីរបបសន្តិសុខសង្គមឬជំនួយសង្គមទេ ព្រោះគាត់គ្មានប័ណ្ណក្រីក្រ។ ប្រាក់កម្ចីឯកជននោះ គិតការប្រាក់ ១០.០០០រៀលក្នុងមួយថ្ងៃ សម្រាប់កម្ចី ១.០០០។០០០រៀល។ នេះមានន័យថាគាត់ត្រូវបង់ការប្រាក់ប្រចាំថ្ងៃចំនួន ៤០.០០០ រៀល (ប្រហែល ១០ ដុល្លារអាមេរិក) ដែលសរុបទៅត្រូវបង់ការប្រាក់ចំនួន ១.២០០.០០០ រៀលក្នុងមួយខែ ដែលស្មើនឹងអត្រាការប្រាក់ប្រចាំខែ ៣០ ភាគរយក្នុងមួយខែ។ ដោយសារមិនអាចសងទាំងការប្រាក់ឬប្រាក់ដើមបាននោះ ឥឡូវនេះបំណុលសរុបរបស់របស់គាត់បានកើនដល់ ១៦.០០០.០០០ រៀលទៅហើយ។

ប្រាក់ចំណូលដ៏តិចតួចរបស់អ្នកស្រីរដ្ឋានី ស្ទើរតែមិនអាចបំពេញតម្រូវការប្រចាំថ្ងៃបានទេ។ គាត់មានការលំបាកក្នុងការចំណាយសូម្បីតែទៅលើតម្រូវការសំខាន់ចាំបាច់បំផុតប្រចាំថ្ងៃ ហើយដោយមិនមានលុយសន្សំផងនោះ គាត់ត្រូវតែពឹងទៅលើប្រាក់កម្ចីនៅពេលណាដែលមានភាពអាសន្នកើតឡើង។ ក្នុងឆ្នាំ២០២៣ ពេលកូនស្រីគាត់ចូលរៀនវិទ្យាល័យ នាងត្រូវការម៉ូតូដើម្បីធ្វើដំណើរ។ អ្នកស្រីបានទិញម៉ូតូមួយគ្រឿងតាមរយៈការបង់រំលស់ ប៉ុន្តែប៉ុន្មានខែកន្លងមកនេះ អ្នកស្រីមិនអាចបន្តការបង់ប្រាក់រំលស់នោះបានទៀតទេ។

ជាច្រើនឆ្នាំមកនេះ អ្នកស្រីរដ្ឋានី មានជំងឺលើសឈាម ជាតិស្ករក្នុងឈាមខ្ពស់ និងដុំគីសក្នុងថង់ទឹកប្រមាត់ ដែលសុទ្ធតែត្រូវការថ្នាំជាប្រចាំ។ អាកាសធាតុក្តៅខ្លាំងក៏បានប៉ះពាល់ដល់សុខភាពរបស់គាត់ដែរ ដោយគាត់ត្រូវបង្ខំចិត្តឈប់សម្រាកញឹកញាប់ក្នុងពេលចេញទៅធ្វើការ។

## កិច្ចគាំពារសង្គម និងការទទួលបានការថែទាំសុខភាព

អ្នកស្រីរដ្ឋានី ត្រូវបានគេណែនាំឱ្យស្គាល់សមាគមអាយឌា និងបានចូលជាសមាជិកសមាគម ដែលធ្វើឱ្យគាត់បានចូលរួមប្រជុំ និងភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ។ តាមរយៈការតម្រង់ទិសរបស់សមាគមអាយឌា គាត់បានចុះឈ្មោះជាមួយបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ក្រោមគម្រោងស្វ័យនិយោជន៍ដោយស្ម័គ្រចិត្តសម្រាប់ការថែទាំសុខភាព ដោយត្រូវបង់ ១៥.៦០០ រៀលក្នុងមួយខែ។ ថ្វីបើគាត់មានការលំបាកក្នុងការបង់ភាគទានប្រចាំខែក៏ដោយ ក៏ប្អូនប្រុសរបស់អ្នកស្រី ដែលជាកម្មករអេតចាយដូចគ្នានោះ បានជួយដោយបង់ភាគទានប្រចាំឆ្នាំឱ្យគាត់ ហើយគាត់ព្យាយាមសងត្រឡប់វិញជាប្រចាំខែ ទោះបីជាកម្របានបង់ទៅឱ្យប្អូនប្រុសរបស់គាត់វិញក៏ដោយ។



មុនពេលចុះឈ្មោះជាមួយ ប.ស.ស អ្នកស្រីបានពឹងផ្អែកលើគ្លីនិកឯកជននិងមន្ទីរពេទ្យរដ្ឋ ប៉ុន្តែត្រូវចំណាយខ្ពស់ពេលទៅពិនិត្យម្តងៗ ដោយសារជំងឺរ៉ាំរ៉ៃប្រចាំកាយ។ ក្នុងពេលមួយឆ្នាំកន្លងទៅនេះ ការចុះឈ្មោះជាសមាជិក ប.ស.ស គឺមានតម្លៃមិនអាចកាត់ថ្លៃបាន ដែលអាចឱ្យគាត់អាចទៅមន្ទីរពេទ្យរដ្ឋល្អៗបាន ដោយមិនចាំបាច់ចំណាយប្រាក់ផ្ទាល់ខ្លួន។ ឥឡូវនេះ គាត់អាចទទួលបានការព្យាបាលជាទៀងទាត់នៅមន្ទីរពេទ្យដែលគាត់តែងធ្លាប់ស្រមៃចង់ទៅ។

ទោះបីជាគាត់លែងត្រូវការខ្ចីប្រាក់សម្រាប់ការទៅពេទ្យទៀតក៏ដោយ ក៏បំណុលរបស់គាត់នៅតែបន្តកើន

ឡើងជារៀងរាល់ថ្ងៃ ដោយសារតែគាត់នៅតែមិនអាចសងគេវិញបាន សូម្បីតែការប្រាក់។

អ្នកស្រីវង្ហានីបានមានប្រសាសន៍ថា *«ក្នុងនាមជាកម្មករអេតចាយ ខ្ញុំគ្មានសន្តិសុខការងារនិងគ្មានកិច្ចគាំពារ នៅពេលខ្ញុំឈឺឬជំពាក់បំណុលគេទេ។ ការទទួលបានធានារ៉ាប់រងសុខភាពបានជួយខ្ញុំខ្លាំងណាស់ ប៉ុន្តែបើគ្មានប្រាក់ចំណូលនិងការគាំទ្រដែលមានស្ថិរភាពទេនោះ ខ្ញុំក៏នៅតែមិនអាចរួចផុតពីភាពក្រីក្រនោះបានដែរ»*។

សេចក្តីព្រាង